01369571

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 27 / 12 / 2016
ម៉ោង (Time/Heure): 11:10
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E319/63/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៦

**ជូនចំពោះ÷** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី÷** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន÷** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ÷** សេចក្តីសម្រេចលើចម្លើយតបរបស់ ខៀវ សំផន ទៅនឹងការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ (ឯកសារ E319/63)

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើពីមេធាវីការពារក្តី ខៀវ សំផន ដែលបានដាក់នៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០១៦ (ឯកសារ E319/63/1) ឆ្លើយតបទៅនឹងការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិដែលចុះកាលបរិច្ឆេទថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០១៦ (ឯកសារ E319/63)។ មេធាវីការពារក្តី ខៀវ សំផន ជំទាស់ទៅនឹងការបញ្ជាក់លើឯកសារចំនួន ១២ ក្នុងចំណោមឯកសារដែលបានស្នើសុំដាក់បង្ហាញដោយសហព្រះរាជអាជ្ញាអន្តរជាតិ ពីព្រោះមេធាវីការពារក្តីយល់ឃើញថា ឯកសារទាំងនោះគ្មានភាពពាក់ព័ន្ធ គ្មានប្រយោជន៍ ឬ ជាន់គ្នា ចំពោះកម្មវត្ថុនៃសំណុំរឿង ០០២/០២ (ឯកសារ E319/63/1 កថាខណ្ឌ ៤-៥, ៧, ៩-១០)។ មេធាវីការពារក្តីក៏កត់សម្គាល់ផងដែរថា ឯកសារចំនួន ៤ ក្នុងចំណោមឯកសារដែលបានស្នើសុំដាក់បង្ហាញទាំងនោះ គឺជា

កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលបានផ្តល់សក្ខីកម្មរួចហើយនៅចំពោះមុខ អ.វ.ត.ក ក្នុងសំណុំរឿង ០០២/០២ និងស្នើសុំឱ្យមានការដាក់បង្ហាញខ្សែអាត់សំឡេងនៃកិច្ចសម្ភាសន៍ទាំងនេះផងដែរ។ (ឯកសារ E319/63/1 កថាខណ្ឌ ៦, ១០)។

២. ដូចដែលបានកត់សម្គាល់ដោយមេធាវីការពារក្តី ខៀវ សំផន នីតិវិធីថ្មីសម្រាប់គ្រប់គ្រងការដាក់បង្ហាញឯកសារពីក្នុងសំណុំរឿង ០០៣ និង ០០៤ ទៅក្នុងសំណុំរឿង ០០២/០២ ត្រូវបានបង្កើតឡើងតាមរយៈសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ស.ច.ស.អ) កាលពីថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៦ (ឯកសារ E319/62)។ ស.ច.ស.អ បានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងត្រូវតែបញ្ជាក់លើរាល់សំណើរបស់សហព្រះរាជអាជ្ញាដែលបានស្នើសុំដាក់បង្ហាញសម្ភារៈពីក្នុងសំណុំរឿង ០០៣ និង ០០៤ ហើយក៏អាចស្នើសុំដាក់បង្ហាញឯកសារដោយផ្ទាល់ផងដែរ (ឯកសារ E319/62 កថាខណ្ឌ ២៩-៣០)។ នៅពេលដែលសំណើសុំដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាត្រូវបានបញ្ជាក់រួចហើយនោះ ស.ច.ស.អ នឹងពិចារណាលើសំណើនេះ ហើយមេធាវីការពារក្តីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ អាចដាក់ចម្លើយតបបាន (ឯកសារ E319/62 កថាខណ្ឌ ៣០(iv))។

៣. ជាពិសេស ពុំមានបទប្បញ្ញត្តិណាមួយដែលបានចែងសម្រាប់ក្រុមមេធាវីការពារក្តីនៃសំណុំ-រឿង ០០២/០២ ក្នុងការដាក់ចម្លើយតបទៅនឹងសំណើសុំដាក់បង្ហាញឯកសាររបស់សហព្រះ-រាជអាជ្ញានោះឡើយ។ មេធាវីការពារក្តីក្នុងសំណុំរឿង ០០២/០២ ត្រូវបានលើកយកមកបញ្ជាក់តែនៅក្នុងដំណើរការដាក់បង្ហាញឯកសារ ទាក់ទងទៅនឹងការវាយតម្លៃថាតើ សម្ភារៈថ្មីនោះស្របទៅនឹងលក្ខណ្ឌតម្រូវគ្រប់គ្រាន់ដើម្បីអាចទទួលយកជាភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ ដែរ ឬ យ៉ាងណា (ឯកសារ E319/62 កថាខណ្ឌ ៣០(ii))។ ទោះបីជាមេធាវីការ-ពារក្តី ខៀវ សំផន មានសិទ្ធិជំទាស់ទៅនឹងការទទួលយកនូវរាល់សម្ភារៈណាមួយដែលត្រូវបានដាក់បង្ហាញពីសំណុំរឿង ០០៣ និង ០០៤ ធ្វើជាភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ ក៏ដោយ ក៏មិនទាន់មានសំណើសុំបែបនេះនៅឡើយទេ។ ទោះបីជាយ៉ាងណាក៏ដោយ មេធាវីការពារក្តីពុំមានសិទ្ធិជំទាស់ទៅនឹងសំណើសុំដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា-អន្តរជាតិ ដែលបានកំណត់នៅក្នុងឯកសារ E319/63 នោះឡើយ។

៤. ទាក់ទងនឹងសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ដែលបានស្នើសុំឱ្យដាក់បង្ហាញខ្សែអាត់

សំឡេងនៃកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួន ៤ ដែលត្រូវបានស្នើសុំឱ្យដាក់បង្ហាញនោះ អង្គជំនុំជម្រះយល់ឃើញថាជាការឆាប់រហ័សពេក ដោយសារថាឯកសារទាំងនោះមិនទាន់ត្រូវបានទទួលយក ឬ ស្នើសុំឱ្យទទួលយកនៅឡើយទេ (ឯកសារ E319/63/1 កថាខណ្ឌ ៦, ១០)។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះកត់សម្គាល់លើសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីដែលថា ចម្លើយមុនៗរបស់សាក្សីដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ នឹងត្រូវបានទទួលយកធ្វើជាភ័ស្តុតាង អនុលោមតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះ (ឯកសារ E319/63/1 កថាខណ្ឌ ៦)។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះរម្លឹកអំពីសេចក្តីបង្គាប់ទូទៅរបស់អង្គជំនុំជម្រះដែលឱ្យសហព្រះរាជអាជ្ញាស្នើសុំការអនុញ្ញាតពី ក.ស.ច.ស ដាក់បង្ហាញខ្សែអាត់សំឡេងនៃកំណត់ហេតុនៃការស្តាប់ចម្លើយក្នុងសំណុំរឿង ០០៣ និង ០០៤ ទាំងអស់ ដែលត្រូវបានទទួលយកធ្វើជាភ័ស្តុតាងរួចហើយ ឬ ត្រូវបានស្នើសុំឱ្យទទួលយកធ្វើជាភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ (ឯកសារ E441/2 ទំព័រ ១៤) និងរម្លឹកសហព្រះរាជអាជ្ញាអំពីកាតព្វកិច្ចរបស់ខ្លួនក្នុងការដាក់បង្ហាញឯកសារទាក់ទងនឹងបញ្ហានេះ។

៥. អនុស្សរណៈនេះគឺជាចម្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E319/63/1។